# សេចក្តីប្រកាសព័ត៌មានរួម
# ស្តីពីជំនួបរវាងឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា
# និង
# ឯកឧត្តម Nasser BOURITA រដ្ឋមន្ត្រីការបរទេស សហប្រតិបត្តិការអាហ្វ្រិក
# និងជនអន្តោប្រវេសន៍ម៉ារ៉ុក នៃព្រះរាជាណាចក្រម៉ារ៉ុក
# រ៉ាបា ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

****

១. តបតាមការអញ្ជើញរបស់ **ឯកឧត្តម** Nasser BOURITA រដ្ឋមន្ត្រីការបរទេស សហប្រតិបត្តិការអាហ្វ្រិក និងជនអន្តោប្រវេសន៍ម៉ារ៉ុក **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រម៉ារ៉ុក នៅថ្ងៃទី ២៧ និង២៨ ខែមីនា ឆ្នាំ២០២៣ ។

២. ក្នុងឱកាសទស្សនកិច្ចនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម Rachid TALBI ALAMI ប្រធានសភាម៉ារ៉ុក ផងដែរ។

៣. ក្នុងឱកាសជំនួបទ្វេភាគី នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការបរទេស សហប្រតិបត្តិការអាហ្វ្រិក និងជនអន្តោប្រវេសន៍ម៉ារ៉ុក នៅទីក្រុងរ៉ាបា រដ្ឋមន្ត្រីនៃប្រទេសទាំងពីរ បានផ្លាស់ប្តូរមតិយោបល់គ្នាប្រកបដោយផ្លែផ្កា និងបានសម្តែងនូវទំនុកចិត្តថា ដំណើរទស្សនកិច្ចនេះនឹងផ្តល់ជាកម្លាំងជម្រុញថ្មីដល់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ តាមរយៈការស្វែងរកនូវកិច្ចសហប្រតិបត្តិការ និងការដាក់ចេញនូវគំនិតផ្តួចផ្តើមថ្មីៗបន្ថែមទៀត។

៤. **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានកោតសរសើរចំពោះព្រះរាជកិច្ចដឹកនាំរបស់ **ព្រះមហាក្សត្រ** Mohammed VI និងបានសម្តែងការកោតសរសើរចំពោះការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសម៉ារ៉ុក ក៏ដូចជាគោលនយោបាយដ៏ឈ្លាសវៃរបស់**ព្រះមហាក្សត្រ** ដែលព្រះអង្គមានគោលបំណងធានានូវភាពរីកចម្រើន រុងរឿង និងស្ថិរភាពនៃព្រះរាជាណាចក្រ និងប្រជាជនម៉ារ៉ុក។

៥. ដូចគ្នានេះដែរ **ឯកឧត្តម** Nasser BOURITA បានលើកឡើងពីវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ ដែលកើតមានក្នុងប្រទេសកម្ពុជា ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** និងបានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបំពេញតួនាទីយ៉ាងសំខាន់អស់ជាច្រើនទសវត្សរ៍ក្នុងការធានា សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍជាបន្តបន្ទាប់ នៃព្រះរាជាណាចក្រកម្ពុជា។

៦. រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានកោតសរសើរចំពោះទំនាក់ទំនងដ៏ល្អប្រសើរ ដែលបានចងភ្ជាប់ព្រះរាជាណាចក្រទាំងពីរ ឈានដល់កម្រិតខ្ពស់បំផុត ដែលត្រូវបានកត់សម្គាល់ឡើងតាមរយៈចំណងមិត្តភាព ការគោរពគ្នាទៅវិញទៅមក ការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងការសម្របសម្រួលលើបញ្ហាផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍ទៅវិញទៅមក។

៧. ក្នុងន័យនេះ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តចំពោះការរៀបចំឱ្យមានជំនួបតាមប្រព័ន្ធវីដេអូ កម្រិតថ្នាក់រដ្ឋមន្ត្រីនៃប្រទេសទាំងពីរ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ និងកិច្ចប្រជុំពិគ្រោះយោបល់នយោបាយលើកទី៣រវាងម៉ារ៉ុក-កម្ពុជា ថ្នាក់អគ្គនាយក កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ និងបានសម្តែងការចាប់អារម្មណ៍ក្នុងការជំរុញកិច្ចសន្ទនានយោបាយការទូតទ្វេភាគី។

៨. រដ្ឋមន្ត្រីនៃប្រទេសទាំងពីរ បានគូសបញ្ជាក់អំពីតម្រូវការសម្រាប់ការអភិវឌ្ឍផ្នែកពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ និងបានលើកឡើងពីសក្តានុពលនៃការបង្កើតកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដោយឈរលើទីតាំងរៀងៗខ្លួននៅក្នុងតំបន់អាហ្វ្រិកខាងជើង និងអាស៊ីអាគ្នេយ៍។

៩. ក្នុងន័យនេះ រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានលើកទឹកចិត្តដល់សហគមន៍ធុរកិច្ចនៃប្រទេសទាំងពីរក្នុងការបង្កើនសកម្មភាពពាណិជ្ជកម្ម និងវិនិយោគឲ្យកាន់តែខ្លាំង។

១០. ក្នុងទិសដៅនេះ រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានបង្ហាញនូវឆន្ទៈក្នុងការរៀបចំវេទិកាធុរកិច្ចដ៏សំខាន់មួយនៅប្រទេសម៉ារ៉ុក ឬ នៅកម្ពុជា នាពេលអនាគត។

១១. រដ្ឋមន្ត្រីនៃប្រទេសទាំងពីរក៏បានលើកឡើងអំពីទស្សនៈរួមគ្នារវាងម៉ារ៉ុក និងកម្ពុជាលើបញ្ហាតំបន់ និងអន្តរជាតិមួយចំនួន ព្រមទាំងបានបន្តការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ពហុភាគីនិយម និងរួមចំណែកក្នុងរបៀបវារៈពិភពលោកសម្រាប់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍ។

១២. **ឯកឧត្តម Nasser BOURITA** បានកោតសរសើរចំពោះជោគជ័យនៃការធ្វើជាប្រធានអាស៊ានរបស់កម្ពុជា នៅឆ្នាំ២០២២ និងភាពលេចធ្លោនូវលទ្ធផលនៃកិច្ចប្រជុំកំពូល និងកិច្ចប្រជុំពាក់ព័ន្ធនានាដែលបានធ្វើឡើងនៅកម្ពុជាក្នុងរយៈពេលពេញមួយឆ្នាំមុននេះ។

១៣. ចំពោះសំណើរបស់ម៉ារ៉ុកសុំចូលជាដៃគូសន្ទនាតាមវិស័យជាមួយអាស៊ាន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានបញ្ជាក់សាជាថ្មី ដល់សមភាគីម៉ារ៉ុកអំពីការគាំទ្រយ៉ាងពេញទំហឹងរបស់កម្ពុជាសម្រាប់ការវាយតម្លៃឡើងវិញដោយ លេខាធិការដ្ឋានអាស៊ានលើសំណើម៉ារុក ដោយគោរពតាមដំណើរការនីតិវិធី និងកុងសង់ស៊ីសអាស៊ាន។

១៤. ចំពោះបញ្ហានៅតំបន់សាហារ៉ា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** នៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ថា កម្ពុជាសូមគាំទ្រយ៉ាងពេញទំហឹង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អគ្គ

លេខាធិការអង្គការសហប្រជាជាតិ និងប្រេសិតផ្ទាល់របស់ឯកឧត្តមអគ្គលេខាធិការសម្រាប់សាហារ៉ា ដោយអនុលោមតាមវិធានការណ៍ ដែលបានកំណត់ដោយសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនានា ពាក់ព័ន្ធនឹងបញ្ហានេះ និងកោតសរសើរកិច្ចខំប្រឹងប្រែងដ៏ម៉ឺងម៉ាត់ ជាក់ស្តែង និងគួរឲ្យជឿជាក់របស់ប្រទេសម៉ារ៉ុក។

ក្នុងន័យនេះ កម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះអធិបតេយ្យភាព និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រម៉ារ៉ុក និងគោរពកិច្ចខំប្រឹងប្រែងរបស់ម៉ារ៉ុក ដើម្បីឈានទៅដល់ការចរចានយោបាយចំពោះជម្លោះក្នុងតំបន់នេះ។

១៥. រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានស្វាគមន៍ចំពោះការបោះឆ្នោត និងការគាំទ្រគ្នាទៅវិញទៅមក នៅក្នុងក្របខណ្ឌអង្គការអន្តរជាតិ។

១៦. ក្នុងន័យនេះ **ឯកឧត្តម Nasser BOURITA** បានរំលឹកជាថ្មីម្តងទៀតនូវការគាំទ្ររបស់ប្រទេសម៉ារ៉ុក ចំពោះបេក្ខភាពនៃព្រះរាជាណាចក្រកម្ពុជា ជាសមាជិកសង្កេតការណ៍នៃអង្គការសហប្រតិបត្តិការឥស្លាម (OIC)។

១៧. ដូចគ្នានេះដែរចំពោះទំនាក់ទំនងមិត្តភាពដែលផ្សារភ្ជាប់ព្រះរាជាណាចក្រទាំងពីរ ក៏ដូចជា ការដឹកនាំរបស់ប្រទេសម៉ារ៉ុក ក្នុងការចូលរួមថែរក្សាសន្តិសុខអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានសម្តែងនូវការគាំទ្ររបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះបេក្ខភាពរបស់ប្រទេសម៉ារ៉ុកជាសមាជិកមិនអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រាប់អាណត្តិឆ្នាំ២០២៨-២០២៩។

១៨. ចំពោះការទូតសភាវិញ រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានកោតសរសើរនូវការផ្លាស់ប្តូរទស្សនកិច្ចរវាងសភាម៉ារ៉ុក និងរដ្ឋសភាកម្ពុជា ទាំងក្នុងកម្រិតទ្វេភាគី ទាំងក្នុងកម្រិតតំបន់ ពិសេស ក្នុងក្របខណ្ឌអន្តរសភាអាស៊ាន (AIPA) និងក្នុងកម្រិតពហុភាគីផងដែរ។ រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានទទួលស្គាល់ផងដែរនូវកិច្ចសហប្រតិបត្តិការជាវិជ្ជមាននៃសភាទាំងពីរ ហើយបានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការប្រកាន់ខ្ជាប់នូវពហុភាគីនិយមដោយផ្អែកលើច្បាប់អន្តរជាតិ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ក្នុងការបង្កើនបណ្តាញក្រុមសភានៃចលនាមិនចូលបក្សសម្ព័ន្ធ (NAM-PN) ដើម្បីការពារ ថែរក្សា និងលើកកម្ពស់សន្តិភាព និងការអភិវឌ្ឍប្រកប ដោយចីរភាព។ រដ្ឋមន្ត្រីទាំងពីរ ក៏បានពិនិត្យឡើងវិញនូវកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអន្តរសភាពអាស៊ាន AIPA ដែលម៉ារ៉ុកជាសមាជិកសង្កេតការណ៍។

១៩. រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានផ្លាស់ប្តូរយោបល់គ្នា រិះរកគ្រប់វិធី និងមធ្យោបាយ ដើម្បីអភិវឌ្ឍនូវទំនាក់ទំនងរវាងប្រជាជន និងប្រជាជន តាមរយៈការផ្តល់នូវអាហារូបករណ៍ ការផ្លាស់ប្តូរការសិក្សា ស្រាវជ្រាវ ការរៀបចំព្រឹត្តិការណ៍វប្បធម៌។ល។

២០. នៅចុងបញ្ចប់នៃជំនួប រដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានឯកភាពគ្នា នូវផែនទីបង្ហាញផ្លូវមួយនាពេលដ៏ខ្លីខាងមុខ ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីឱ្យកាន់តែស៊ីជម្រៅ ក្នុងគោលបំណងបង្កើតនូវភាពជាដៃគូគ្រប់ជ្រុងជ្រោយ។

២១. រដ្ឋមន្ត្រីនៃប្រទេសទាំងពីរ ស្វាគមន៍ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រម៉ារ៉ុក និងបានបង្ហាញពីទំនុកចិត្តថា កិច្ចព្រមព្រៀងនេះនឹងជួយរួមចំណែកដល់ការលើកកម្ពស់វិស័យទេសចរណ៍ ធុរកិច្ច និងការតភ្ជាប់រវាងប្រជាជននិងប្រជាជននៃប្រទេសទាំងពីរ។

២២. ក្នុងស្មារតីដូចគ្នា រដ្ឋមន្ត្រីទាំងពីរបានឯកភាពធ្វើការពន្លឿនការចរចារបញ្ចប់ និងឈានទៅរកចុះការហត្ថលេខាលើកិច្ចព្រមព្រៀងដែលមិនទាន់សម្រេចចំនួន ០៣ ផ្សេងទៀត រួមមាន៖

- កិច្ចព្រមព្រៀងស្តីពីការជម្រុញ និងការការពារវិនិយោគទៅវិញទៅមករវាងព្រះរាជាណាចក្រម៉ារ៉ុក និងព្រះរាជាណាចក្រកម្ពុជា។
- កិច្ចព្រមព្រៀង ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ រវាងព្រះរាជាណាចក្រម៉ារ៉ុក និងព្រះរាជាណាចក្រកម្ពុជា
- កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រ និងសេដ្ឋកិច្ច។

ឯកសារទាំងបីនេះ នឹងផ្តល់សន្ទុះថ្មីដល់សេដ្ឋកិច្ច ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងជាមូលដ្ឋានរឹងមាំសម្រាប់ការជំរុញសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគ ដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងដ៏ល្អប្រសើរដែលភ្ជាប់ប្រទេសទាំងពីរទាំងកម្រិតនយោបាយ និងការទូត។

២៣. លើសពីនេះទៅទៀត និងដោយផ្អែកលើគោលដៅ និងគោលបំណងរួមសម្រាប់ការលើកកម្ពស់ទំនាក់ទំនងទ្វេភាគី និងកិច្ចការផ្សេងទៀត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា** នឹងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសម៉ារ៉ុក តបតាមការអញ្ជើញរបស់ ឯកឧត្តម Aziz AKHANNOUCH ប្រមុខរាជរដ្ឋាភិបាលម៉ារ៉ុក។

២៤. **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានស្នើអញ្ជើញ **ឯកឧត្តម Nasser BOURITA** រដ្ឋមន្ត្រីការបរទេស សហប្រតិបត្តិការអាហ្វ្រិក និងជនអន្តោប្រវេសន៍ម៉ារ៉ុក មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជានាពេលខាងមុខ។ **ឯកឧត្តម Nasser BOURITA** បានទទួលយកនូវការអញ្ជើញនេះដោយក្តីសោមនស្សរីករាយ។